ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# សេចក្តីថ្លែងការណ៍

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សម្តែងនូវការសោកស្តាយចំពោះហេតុការណ៍នៅតំបន់ព្រំដែនកម្ពុជា-ថៃ នៅព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ដែលកងកម្លាំងប្រដាប់អាវុធថៃ បានបើកការវាយប្រហារដោយមានមូលហេតុឈ្លានពាន គិតទុកជាមុន និងដោយចេតនា មកលើទីតាំងឈរជើងរបស់កម្ពុជា នៅតាមតំបន់ព្រំដែន រួមទាំង ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី តំបន់មុំបី និងតំបន់ផ្សេងៗទៀត នៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ថ្កោលទោសចំពោះទង្វើឈ្លានពានឃោរឃៅយ៉ាងគឃ្លើនរបស់កងកម្លាំងប្រដាប់អាវុធថៃ មកលើអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ដែលបានបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ រួមទាំងគោលការណ៍មូលដ្ឋានដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ដែលអាចប៉ះពាល់ដល់ដំណើរការកសាងសហគមន៍អាស៊ានសន្តិភាព។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សូមគាំទ្រចំពោះតួនាទីដែលមិនអាចខ្វះបានរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការចូលរួមចំណែកបញ្ជាកងទ័ព ជាមួយនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ អគ្គមេបញ្ជាការកងទ័ព និងបញ្ជាការកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ដើម្បីឆ្លើយតបប្រឆាំងនឹងការឈ្លានពាន ដោយប្រដាប់អាវុធរបស់ថៃ ដែលជាសិទ្ធិស្វ័យការពារខ្លួនក្នុងកិច្ចការពារដែនអធិបតេយ្យភាព បូរណភាពទឹកដី ជីវិតប្រជាពលរដ្ឋ និងឧត្តមប្រយោជន៍របស់ជាតិកម្ពុជា។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ប្រកាសគាំទ្រ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការផ្ញើលិខិតទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្នើសុំកោះប្រជុំក្រុមប្រឹក្សាសន្តិសុខជាបន្ទាន់ ដើម្បីសុំការអន្តរាគមន៍បញ្ឈប់ការឈ្លានពានរបស់កម្លាំងប្រដាប់អាវុធថៃមកលើដែនអធិបតេយ្យភាពរបស់កម្ពុជា។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** សូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូបរក្សាសាមគ្គីភាពគ្នាជាធ្លុងមួយ បន្តប្រកបរបរប្រចាំថ្ងៃជាប្រក្រតី និងសូមជឿជាក់ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពកម្ពុជា ដែលកំពុងឈរជើងការពារបូរណភាពទឹកដី នៅសមរភូមិមុខ។

**រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ជឿជាក់ថា យុត្តិធម៌ផ្អែកលើច្បាប់អន្តរជាតិនឹងនាំមកនូវសន្តិភាពយូរអង្វែង តាមចក្ខុវិស័យដឹកនាំសន្តិភាពរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានប្រកាសនៅក្នុងសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ ហើយដែលរាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជូនវិវាទនៅតំបន់មុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី ទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥